ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៩៦/០៩- ស៊ូតវៃ**

**កាលបរិច្ឆេទនៃសេចក្ដីសម្រេច : ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩**

# សេចក្ដីសម្រេចអាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្ដីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក: **លី តៃសេង**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ: **គង់ ផល្លះ**

**ភាគីនៃវិវាទ**

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ស៊ុន ទេ ឡាវីសាកា ហ្វេសិន ហ្វេកតើរី លីមីតធីត**

អាសយដ្ឋាន : ផ្លូវសង់ថ្មី ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៥៤១ ០៥៦ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោកស្រី ចុង ម៉ីលីង | ជំនួយការនាយក |
| ២- លោកស្រី មិន ស៊ូភីង | រដ្ឋបាលក្រុមហ៊ុន |

២- **ភាគីកម្មករនិយោជិត**

**ឈ្មោះ : សហព័ន្ធសហជីព-សហជីពការងារកម្មករកម្ពុជា ក្រុមហ៊ុន ស៊ូតវៃ**

អាសយដ្ឋាន : ផ្លូវសង់ថ្មី ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ២៥៨ ០០៦ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក ឈិន សូនី | អនុប្រធានសហព័ន្ធសហជីពការងារកម្មករកម្ពុជា |



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

២- លោក ឯក សុខជា អគ្គលេខាធិការសហព័ន្ធសហជីពការងារកម្មករកម្ពុជា

៣- កញ្ញា សេង ស៊ីវន លេខាធិការសហជីពការងារកម្មករកម្ពុជា ក្រុមហ៊ុន ស៊ូត វៀ

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី២ ប្រចាំរោងចក្រ ស៊ូតវៀ ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញបញ្ជិកាលេខ ១១៦ កប.អក.រក. ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩។

២- ក្រុមហ៊ុនមិនត្រូវបង្ខំកម្មករនិយោជិតឱ្យធ្វើការបន្ថែមម៉ោង។

៣- ក្រុមហ៊ុនមិនត្រូវធ្វើការព្រមានកម្មករនិយោជិត ដោយគ្មានហេតុផលត្រឹមត្រូវ តាមច្បាប់ស្តីពីការងារ។

៤- សុំឱ្យក្រុមហ៊ុនរៀបចំធ្វើកន្លែងដាក់កង់ ម៉ូតូ ឱ្យបានត្រឹមត្រូវ។

៥- សុំឱ្យក្រុមហ៊ុនសំរួលដល់ការសុំច្បាប់របស់កម្មករនិយោជិត និងមិនត្រូវកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់បន្ទាប់បន្សំផ្សេងៗ ពេលដែលកម្មករនិយោជិតដាក់ច្បាប់ឈឺ មានសំបុត្រពេទ្យបញ្ជាក់ត្រឹមត្រូវ។

៦- សុំឱ្យក្រុមហ៊ុនបើកលុយថែមម៉ោងមួយសប្តាហ៍ម្តង ដើម្បីដោះស្រាយនូវតំរូវការចាំបាច់ក្នុងជីវភាព។

៧- សុំឱ្យក្រុមហ៊ុនចេញតំលៃបុងឱ្យកម្មករនិយោជិតបានដឹងមុន ដើម្បីឱ្យកម្មករនិយោជិតមានកំលាំងចិត្តក្នុងការផលិត។

៨- សុំឱ្យក្រុមហ៊ុនផ្តល់ទឹកស្អាតសំរាប់កម្មករនិយោជិតហូបឱ្យបានគ្រប់គ្រាន់ និងមានសាប៊ូលាងដៃ ដើម្បីសុខភាពរបស់កម្មករនិយោជិត។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៥៨៥ ក.ប/អក/វ.ក ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩ ( វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**បញ្ហានីតិវិធី :**

នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងរបស់សហព័ន្ធសហជីពការងារកម្មករកម្ពុជា ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានប្រសើរ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ ប៉ុន្តែមិនបានទទួលលទ្ធផលសះជា លើការទាមទារទាំងអស់ចំនួន០៨ចំណុចទេ ។ ចំណុចមិនសះជាចំនួន០៨ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន០៨ចំណុចនេះ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ( វេលាម៉ោង ១៤:០០ នាទី) ។ ភាគីទាំងពីរមានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចវិវាទចំនួន០៨ចំណុចនេះម្តងទៀត ហើយបានទទួលលទ្ធផលសះជាចំនួន០៧ចំណុច នៅសល់ចំណុចវិវាទទី១ ។ ដូច្នេះ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើការទាមទារតែចំណុចវិវាទទី១នេះប៉ុណ្ណោះ ដោយផ្អែកលើភស្តុតាង និង ហេតុផលដូចខាងក្រោម:

## ភស្តុតាង

**សាក្សី និង អ្នកជំនាញក្រៅពីភាគី :** គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតប្រគល់សិទ្ធិជូនឈ្មោះ ចុង ម៉ិលីន និង ឆិន ស៊ូភីង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពការងារកម្មករកម្ពុជារោងចក្រកាត់ដេរ ស៊ូតរ៉ៅ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០២ ។

២- លិខិត លេខ ១៨៣ កប/អក/វក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជិកាពេញច្បាប់ ។

៣- លិខិត លេខ ១១៦ កប/អក/វក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី២។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស៊ូតវ៉ េ លេខ ៥៨៥ ក.ប/អក/វ.ក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ស៊ូតវ៉ េ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៤៧៥ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៤៧៦ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩។

៣- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីអាជ្ញាកណ្តាលស្នើដោយសមាគមនិយោជក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន ស៊ូតវ៉ េ មានជួលកម្មករនិយោជិតសរុបប្រហែល ៦០០ នាក់។
- សហជីពការងារកម្មករកម្ពុជា ដែលជាដើមបណ្តឹងក្នុងរឿងនេះ បានបង្កើតឡើងនៅឆ្នាំ២០០២ តាមរយៈបញ្ជិកាលេខ ២៦៨ សកបយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០២ ហើយមានសមាជិកប្រហែល ២២៤ នាក់។ សហជីពនេះគ្មានភាពជាតំណាងបំផុតទេ។
- នាយកដ្ឋានវិវាទការងារបានចេញលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី( អាណត្តិទី ២) នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩។
- សហជីពបានទាមទារឱ្យក្រុមហ៊ុនទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី ព្រោះសហជីពមានបញ្ជិកា ឆ្នាំ២០០២ និងលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីព ឆ្នាំ២០០៩។ ប៉ុន្តែក្រុមហ៊ុនមិនទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មីនេះទេ ព្រោះគ្មានបញ្ជិកាសហជីពថ្មី សម្រាប់ឆ្នាំ២០០៩។

**ហេតុផលនៃសេចក្តីសម្រេចៈ**

ភាគីកម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនទទួលស្គាល់ថ្នាក់ដឹកនាំថ្មីរបស់សហជីពការងារកម្មករកម្ពុជារោងចក្រកាត់ដេរ ស៊ូតវៃ ដែលមានឈ្មោះ **សហជីពការងារកម្មករកម្ពុជារោងចក្រកាត់ដេរ ស៊ូតវៃ** ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញវិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពលេខ ២៦៨ សកបយ. ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ២០០២។ នាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានចេញលិខិតលេខ ១១៦ កប/អក/វក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ ដើម្បីទទួលស្គាល់ថ្នាក់ដឹកនាំថ្មីរបស់សហជីពសម្រាប់អាណត្តិទី២។ ឯភាគីក្រុមហ៊ុនវិញនៅតែមិនទទួលស្គាល់ថ្នាក់ដឹកនាំថ្មីរបស់សហជីពការងារកម្មករកម្ពុជារោងចក្រកាត់ដេរ ស៊ូតវៃ នោះទេ ទាល់តែសហជីពមានបញ្ជិកាថ្មីពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើក្រុមហ៊ុនត្រូវទទួលស្គាល់ថ្នាក់ដឹកនាំថ្មីរបស់សហជីពការងារកម្មករកម្ពុជារោងចក្រកាត់ដេរ ស៊ូតវៃ ដែរ ឬទេ?

មាត្រា ២៦៨ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា " *ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយ ដែលច្បាប់ការងារនេះទទួលស្គាល់ ស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនោះ ត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ និងកិច្ចការរដ្ឋបាលទៅតំកល់ទុកនៅក្រសួងទទួលបន្ទុកវិស័យការងារដើម្បីសុំចុះបញ្ជិកា។ .......ការតំកល់ទុកនេះត្រូវធ្វើជាថ្មីម្តងទៀតនៅពេល ដែលមានការផ្លាស់ប្តូរលក្ខន្តិកៈ ឬអ្នកដឹកនាំ។*"

បន្ថែមពីនេះទៀត ប្រការ១ ប្រការ៣ និងប្រការ៤ នៃប្រកាសលេខ ០២១ ក.ក.ប.វ/ប្រក. របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៦ ក៏មានចែងដូចខ្លឹមសារនៃមាត្រា ២៦៨ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ខាងលើនេះដែរ ដោយស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនោះ ត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ និងកិច្ចការរដ្ឋបាល ទៅតំកល់ទុកនៅក្រសួងទទួលបន្ទុកវិស័យការងារដើម្បីទៅសុំចុះបញ្ជិកាពីក្រសួង ហើយការតំកល់នេះត្រូវធ្វើជាថ្មីម្តងទៀត នៅពេលដែលមានការផ្លាស់ប្តូរ។

ផ្អែកតាមអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពការងារកម្មករកម្ពុជាមានបញ្ជិកាលេខ ២៦៨ សកបយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០២ និងលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី ២ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលចេញដោយនាយកដ្ឋានវិវាទការងារ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពនេះជាសហជីព ដែលបង្កើតឡើងស្របតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជាហើយ។

ចំពោះការលើកឡើងរបស់និយោជក ដែលលើកឡើងថា ទាល់តែសហជីពមានបញ្ជិកាថ្មីពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទើបទទួលស្គាល់ថ្នាក់ដឹកនាំថ្មីរបស់សហជីពការងារកម្មករកម្ពុជារោងចក្រកាត់ដេរ ស៊ូតវៃ នោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លិខិតទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺ

ជាលិខិត ដែលមានអនុភាពផ្លូវច្បាប់ ដែលអះអាងថា ការជ្រើសរើសថ្នាក់ដឹកនាំថ្មីនេះ គឺត្រឹមត្រូវតាមនីតិវិធីរបស់ច្បាប់ហើយ ។ ហេតុនេះ មូលហេតុរបស់ក្រុមហ៊ុនជាមូលហេតុ ដែលមិនសមស្របឡើយ ។ ដូច្នេះ ផ្អែកតាមច្បាប់ស្តីពីការងារ ភាគីនិយោជកត្រូវតែទទួលស្គាល់សហជីព និងថ្នាក់ដឹកនាំសហជីព ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានទទួលស្គាល់ ហើយភាគីសហជីពមិនចាំបាច់សុំឱ្យក្រុមហ៊ុនទទួលស្គាល់ថ្នាក់ដឹកនាំសហជីពរបស់ខ្លួនឡើយ ព្រោះការទទួលស្គាល់ថ្នាក់ដឹកនាំសហជីពមិនមែនជា សមត្ថកិច្ចរបស់ក្រុមហ៊ុនទេ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់សហជីពមិនត្រឹមត្រូវទេ ព្រោះការទទួលស្គាល់ថ្នាក់ដឹកនាំ សហជីព គឺជាសមត្ថកិច្ចរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ សហជីព គួរតែសុំឱ្យក្រុមហ៊ុនសហការ ឬធ្វើការសហការជាមួយក្រុមហ៊ុន ដើម្បីការពារផលប្រយោជន៍របស់កម្មករ និយោជិតទើបជាការត្រឹមត្រូវ ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទាររបស់សហជីព និងបង្គាប់ឱ្យក្រុមហ៊ុនសហការជាមួយសហជីពក្នុងការដោះស្រាយបញ្ហាវិវាទរបស់កម្មករនិយោជិត ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

- បដិសេធការទាមទាររបស់សហជីពការងារកម្មករកម្ពុជារោងចក្រកាត់ដេរ ស៊ូតវៃ ឱ្យក្រុមហ៊ុនទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី ។
- បង្គាប់ឱ្យក្រុមហ៊ុនសហការជាមួយថ្នាក់ដឹកនាំសហជីពថ្មីរបស់សហជីពការងារកម្មករកម្ពុជារោងចក្រកាត់ដេរ ស៊ូតវៃ ដែលបានទទួលស្គាល់ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **លី តៃសេង**

ហត្ថលេខា: ------------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អាន វីរៈ**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------